# តើអ្វីជា ការផ្តាច់ចរន្តអគ្គិសនីដើម្បីសុវត្ថិភាពសាធារណៈ?

**វីដេអូ៖**

ការផ្តាច់ចរន្តអគ្គិសនីដើម្បីសុវត្ថិភាពសាធារណៈ ឬ PSPS គឺជាវិធានសុវត្ថិភាពប្រុងប្រយ័ត្នជាមុន ដែលត្រូវបានអនុវត្តក្រោយភ្លើងឆេះព្រៃកាលពីឆ្នាំ 2017 និង 2018 ដែលអាចនឹងបិទខ្សែថាមពលបាន យ៉ាងសកម្មជាមុន នៅពេលស្ថានភាពគ្រោះថ្នាក់នៃអគ្គិភ័យត្រូវបានព្យាករណ៍ទុកដោយប្រើប្រាស់បណ្តាញ នៃស្ថានីយ៍អាកាសធាតុរបស់យើង។

ខណៈពេលសហគមន៍នៅក្នុងតំបន់ដែលមានការគំរាមកំហែងពីអគ្គិភ័យកម្រិតខ្ពស់ គឺទំនងជានឹង ត្រូវបានប៉ះពាល់ធ្ងន់ធ្ងរបំផុត រាល់អតិថិជនរបស់ PG&E គួរតែបានប្រុងប្រៀបខ្លួនទុកជាមុនចំពោះ ការផ្តាច់ចរន្តអគ្គិសនីដើម្បីសុវត្ថិភាពសាធារណៈដែលអាចកើតមានឡើង។

ពីព្រោះខ្សែថាមពលអាចបម្រើសហគមន៍នៅចំងាយជាច្រើនម៉ាយ ទោះបីជាអតិថិជនដែលមិនរស់នៅ ក្នុងតំបន់ដែលមានការគំរាមកំហែងពីអគ្គិភ័យកម្រិតខ្ពស់ ឬមិនកំពុងជួបប្រទះនឹងអាកាសធាតុ ធ្ងន់ធ្ងរក៏ដោយ ក៏អាចនឹងបាត់បង់ចរន្តអគ្គិសនីដែរ។

ដូច្នេះ ទោះបីជាមិនមានស្ថានភាពខ្យល់បក់ខ្លាំង ឬស្ថានភាពគ្រោះថ្នាក់នៅកន្លែងដែលអ្នករស់ នៅក៏ដោយ ក៏ចរន្តអគ្គិសនីរបស់អ្នកអាចនឹងត្រូវបានផ្តាច់ ដោយសារតែអ្នកត្រូវបានបម្រើដោយខ្សែថាមពលដែលត្រូវបានរងផលប៉ះពាល់ដោយស្ថានភាពទាំង នោះ។

វាជាការសំខាន់ដែលអតិថិជនរបស់យើងបង្កើតផែនការ ដើម្បីរក្សាខ្លួនពួកគេឲ្យមានសុវត្ថិភាពអំឡុង រដូវកាលភ្លើងឆេះព្រៃ។

ដើម្បីស្វែងយល់បន្ថែមអំពីការផ្តាច់ចរន្តអគ្គិសនីដើម្បីសុវត្ថិភាពសាធារណៈ ឬស្វែងយល់ អំពីគន្លឹះដើម្បីប្រុងប្រៀបខ្លួនកាន់តែប្រសើរចំពោះការផ្តាច់ចរន្តអគ្គិសនី សូមចូលទៅកាន់ safetyactioncenter.pge.com ។